CITY OF
LONG BEACH

**4/15/2020**

សំរាប់ផ្សព្វផ្សាយបន្ទាន់ សេចក្តីប្រកាសពត៌មាន # 041520B

**ប្រធានបទ:** **ក្រុមប្រឹក្សាក្រុង ឬចៅសង្កាត់ ចាត់វិធានការដើម្បីសង្គ្រោះសេដ្ឋកិច្ច**

**ទំនាក់ទំនង:** មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីធ
562.570.NEWS (ការសាកសួររបស់ប្រព័ន្ធពត៌មានតែប៉ុណ្ណោះ)
jic@longbeach.gov (ការសាកសួររបស់ប្រព័ន្ធពត៌មានតែប៉ុណ្ណោះ)
ប្រជាពលរដ្ឋ: សូមទូរស័ព្ទលេខ 562.570.INFO

ក្រុងឡុងប៊ីធ, រដ្ឋកាលីហ្វ័រញ៉ា — កាលពីម្សិលមិញ ក្រុមប្រឹក្សាក្រុង បានអនុម័តជាឯកច្ឆ័ន្ទ នូវសកម្មភាពដាច់ដោយឡែកចំនួន ២៥ ទាក់ទងនឹងកញ្ចប់ជំនួយសង្គ្រោះសេដ្ឋកិច្ចក្នុងតំបន់ជាប្រវត្តិសាស្ត្រ ដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់ក្រុមគ្រួសារដែលកំពុងធ្វើការ និងម្ចាស់អាជីវកម្មខ្នាតតូច ដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត COVID-19។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “ខ្ញុំមានមោទនភាពដែលកញ្ចប់ជំនួយសង្គ្រោះសេដ្ឋកិច្ចនេះ ការពារកម្មករ និងអាជីវកម្មខ្នាតតូច,”។ “ប្រជាពលរដ្ឋរស់នៅក្រុងឡុងប៊ិច សមនឹងទទួលបានពេលវេលាឈឺ ក្នុងកំឡុងពេលមានវិបត្តិសុខភាពនេះ ហើយអាជីវកម្មខ្នាតតូចរបស់យើងទាំងឡាយ ត្រូវការនូវប្រាក់កម្ចី និងមានលទ្ធភាព ដើម្បីទទួលបានជំនួយផ្សេងៗ”។

កម្មវិធីផែនការជំនួយសេដ្ឋកិច្ចទូលំទូលាយ នឹងជួយក្រុមគ្រួសារដែលកំពុងធ្វើការ និងម្ចាស់អាជីវកម្មខ្នាតតូចទាំងឡាយ ដោះស្រាយនូវតម្រូវការសំខាន់ៗដូចតទៅនេះ, ក្នុងចំណោមតំរូវការផ្សេងៗនានា៖

- ដើម្បីបំពេញការខ្វះខាត ឬចន្លោះប្រហោងនានា នៃគោលនយោបាយឈប់សម្រាកឈឺបន្ថែម របស់សហព័ន្ធ, មេធាវីក្រុង នឹងព្រាងបទបញ្ញត្តិដែលតម្រូវអោយនិយោជិកនៅឡុងប៊ិធ ដែមាននិយោជិកច្រើនជាង ៥០០ នាក់នៅទូទាំងប្រទេស ផ្តល់ការឈប់សម្រាកឈឺបន្ថែម។
- ដើម្បីជួយដល់សណ្ឋាគារ និងម៉ូតែលនានា ដែលបានរងនូវផលប៉ះពាល់, បង្កើតនូវក្រុមការងារស្តារបដិសណ្ឋារកិច្ច ដើម្បីរៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រនានា សម្រាប់ការស្តារឡើងវិញនៃភ្ញៀវទេសចរ អាជីវកម្មធ្វើដំណើរទេសចរណ៍កំសាន្ត និងបន្ទប់ស្នាក់នៅយប់ទាំងឡាយ នៅក្នុងឡុងប៊ីធ។
- ដើម្បីជួយដៃគូអ្នកបណ្តាំទ្រព្យសម្បត្តិ ជាមួយអង្គការមិនរកប្រាក់ចំណេញ ដើម្បីលើកកម្ពស់កម្មវិធីការពារការរឹបអូសទ្រព្យសម្បត្តិរដ្ឋ និងសហព័ន្ធ, និងធ្វើការជាមួយការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយអង្គការមិនស្វែងរកប្រាក់ចំណេញនានា ឬជាមួយសាជីវកម្មអភិវឌ្ឍន៍សហគមន៍ ដើម្បីបង្កើតនូវកម្មវិធីជំនួយការបណ្តាំទ្រព្យសម្បត្តិ។
- ដើម្បីជួយដល់បុគ្គលិកសណ្ឋាគារ និងកម្មករបោសសំអាត ដែលត្រូវបានបញ្ឈប់ពីការងារ, មេធាវីស៊ីធីនឹងធ្វើសេចក្តីព្រាងបទបញ្ញត្តិមួយ ដើម្បីផ្តល់ការរក្សាទុកនូវកម្មករ និងគោលនយោបាយហៅមកធ្វើការវិញ (recall policies)។

CITY OF LONG BEACH

- ដើម្បីផ្តល់ដើមទុនសំរាប់ចាប់ផ្តើមដំណើរការ ឬទុនធ្វើការដល់អាជីវកម្មខ្នាតតូចក្នុងស្រុក និងអង្គការមិនរកប្រាក់ចំណេញនានាទាំងឡាយ ដែលមិនអាចធានា ឬសងបាននូវប្រាក់កម្ចីរបស់សហព័ន្ធក្រុង, ស៊ីធីបានអនុម័តការបង្កើតនូវកម្មវិធីកំចីមីក្រូ ឬកំចីខ្នាតតូចសង្គ្រោះបន្ទាន់ថ្មី។
- ដើម្បីការពារសុខភាពទាំងអតិថិជន និងទាំងកម្មករ, មន្ត្រីសុខភាពក្រុង បានបង្កើតពិធីសារថ្មី រួមបញ្ចូលនូវ បញ្ជីត្រួតពិនិត្យអាជីវកម្មខ្នាតតូចថ្មីមួយ ដែលងាយស្រួលសំរាប់អ្នកប្រើ និងត្រូវបិទផ្សាយនៅតាមគ្រប់អាជីវកម្មសំខាន់ៗទាំងអស់ ត្រឹមថ្ងៃទី១៥ ខែមេសា។
- ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មាន ដល់ប្រជាពលរដ្ឋអោយបានកាន់តែច្រើន ស្តីអំពីសេវាកម្មគាំទ្រក្នុង/ជាភាសាផ្សេងៗច្រើនភាសា ស៊ីធីនឹងធ្វើការពង្រីកកម្មវិធីទទួលបាននូវភាសា (Language Access Program) របស់ខ្លួន។
- ដើម្បីជួយដល់ប្រជពលរដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងខ្លួនឯង ឬកំពុងដាក់ខ្លួនឯងអោយនៅដាច់គេ (self-quarantine) បានដោយសុវត្ថិភាព ដោយធ្វើការផ្តល់អាទិភាពលើមនុស្សចាស់។ គណៈគ្រប់គ្រងស៊ីធី នឹងបន្តផ្តល់នូវធនធានបច្ចុប្បន្ននានាទាំងឡាយ និងធ្វើការពង្រីកនូវឱកាសនានា ដើម្បីជួយដល់អ្នកដែលមានតំរូវការជាពិសេស ប្រជាពលរដ្ឋដែលមានអាយុលើសពី៦០ ឆ្នាំ។
- ដើម្បីធ្វើអោយកម្មវិធីទាំងអស់នេះ កាន់តែមានភាពងាយស្រួលក្នុងការមកទទួល សម្រាប់កម្មករក្នុងស្រុក និងម្ចាស់អាជីវកម្មខ្នាតតូចទាំងឡាយ ស៊ីធីផ្តល់នូវធនធាននានាជាច្រើន, រួមបញ្ចូលនូវ:
  - ហាតឡាញ, 562-570-INFO (4636), សំរាប់សំណួរទូទៅ អំពី COVID-19
  - ហាតឡាញ, 562-570-4BIZ (4249), សំរាប់អាជីវកម្ម និងកម្មករ
  - A new website for businesses and workers
  - វេបសាយ សំរាប់ធនធាន ព័ត៌មាន COVID-19
  - វេបសាយ សំរាប់ធនធាន អាជីវកម្ម និងកម្មករ
- ដើម្បីប្រមូល និងចែកចាយនូវអំណោយទាំងឡាយដល់អង្គការនានា ដែលកំពុងជួយដល់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារជំងឺ COVID-19, ស៊ីធីបានបង្កើតនូវមូលនិធិសង្គ្រោះគ្រោះមហន្តរាយឡុងប៊ិច, ក្នុងភាពជាដៃគូជាមួយនិង មូលនិធិសហគមន៍ឡុងប៊ិច (Long Beach Community Foundation)។
- ដើម្បីភ្ជាប់ជាមួយនិងមនុស្សដែលចង់ស្ម័គ្រចិត្តនូវពេលវេលា ឬធនធាននានារបស់ពួកគេ ដើម្បីជួយដល់អ្នកដទៃទាំងឡាយ ដែលកំពុងដាក់ខ្លួនឯងអោយនៅដាច់គេ, វេបសាយអ្នកស្ម័គ្រចិត្តថ្មីមួយ ត្រូវបានបង្កើតឡើង។

ស៊ីធីនឹងបន្តធ្វើបច្ចុប្បន្នភាព ធនធានទាំងអស់នេះ ដោយ:

- បន្តស្វែងរកជំនួយ និងអំណោយ ឬការបរិច្ចាគនានា ដើម្បីទទួលបានផលចំណេញដល់អង្គការមិនរកប្រាក់ចំណេញទាំងឡាយ ដើម្បីលើកកម្ពស់ភាពចម្រុះនៃអាហារស្រស់ៗថ្មីៗ ឬទំនិញផ្សេងៗទៀត អោយទៅដល់អ្នកទាំងឡាយ ដែលកំពុងដាក់ខ្លួនឯងអោយនៅដាច់គេ។
- បន្ថែមធនធាននានា ទៅដល់មជ្ឈមណ្ឌលហៅទូរស័ព្ទ និងគេហទំព័រ។
- ធ្វើការលើកកំពស់ភាពជាដៃគូ ជាមួយអង្គការមិនរកប្រាក់ចំណេញក្នុងស្រុក ដើម្បីរក្សាអោយបាន នូវទំនាក់ទំនងជាមួយ មនុស្សដែលកំពុងដាក់ខ្លួនឯងអោយនៅដាច់គេ។

CITY OF LONG BEACH

ប្រធានស៊ីធីឡុងប៊ីឆ លោក Tom Modica និងនាយកអភិវឌ្ឍន៍សេដ្ឋកិច្ច John Keisler បានរៀបចំ និងបានប្រគល់ កញ្ចប់ជំនួយសេដ្ឋកិច្ច។ នៅថ្ងៃទី១៧ ខែមីនា ក្រុមប្រឹក្សាស៊ីធី បានណែនាំ Modica អោយធ្វើការជាមួយនិងមេធាវីស៊ីធី និងមន្ទីរពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការវាយតម្លៃលទ្ធភាព នៃការអនុវត្តនូវកញ្ចប់ជំនួយសេដ្ឋកិច្ច សម្រាប់គ្រួសារដែលកំពុងធ្វើការ និងអាជីវកម្មខ្នាតតូចទាំងឡាយ ដែលទទួលរងនូវផលប៉ះពាល់ដោយគ្រោះមហន្តរាយជំងឺ COVID-19។

បុគ្គលិកបានចុះផ្សព្វផ្សាយដល់មន្ទីរនានារបស់ស៊ីធី ដៃគូវិស័យឯកជន ស្ថាប័នផ្តល់ប្រាក់កម្ចី ម្ចាស់ទ្រព្យសម្បត្តិ និងអង្គការដែលមានមូលដ្ឋាននៅសហគមន៍នានា ដែលមានការប៉ះពាល់ដោយគ្រោះមហន្តរាយ COVID-19  ដើម្បីពិនិត្យឡើងវិញនូវបញ្ហាចំនួន ១២ និងផ្តល់អនុសាសន៍យុទ្ធសាស្ត្រនានា សម្រាប់ធ្វើសេចក្តីពិចារណាដោយក្រុមប្រឹក្សាក្រុង។

បទបញ្ញត្តិទាំងនេះនឹងត្រលប់ទៅកាន់ក្រុមប្រឹក្សាក្រុង ដើម្បីពិនិត្យឡើងវិញ។ ក្រុមប្រឹក្សាក្រុង ត្រូវតែអនុម័តបទបញ្ញត្តិមុនពេលដែលវាមានប្រសិទ្ធភាព។

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីឆកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

# # #

សំរាប់ពត៌មាន, រូបភាព, វីឌីអូ និងសេចក្តីប្រកាសនានាបន្ថែមទៀត នៃអ្វីដែលកំពុងកើតឡើងក្នុងក្រុងឡុងប៊ីឆ តាមមើលពួកយើង លើ Facebook, Twitter, Instagram និង YouTube.